**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ១០៤៩ សជណ

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០០៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ជំរាបមក**
**លោក ស៊ុម ពិសិដ្ឋ ប្រធានអង្គការស្នាក់នៅស្ម័គ្រចិត្តជួយបង្រៀន**

**កម្មវត្ថុ** : អំពីការសុំចុះបញ្ជីរបស់ ***អង្គការស្នាក់នៅស្ម័គ្រចិត្តជួយបង្រៀន*** នៅក្រសួងមហាផ្ទៃ ។

**យោង** : លិខិតលេខ ***០០១ស.ន.ជ.ប*** ចុះថ្ងៃទី ***០១*** ខែ ***សីហា*** ឆ្នាំ ***២០០៨*** ស្តីពីការសុំចុះបញ្ជីរបស់ ***អង្គការស្នាក់នៅស្ម័គ្រចិត្តជួយបង្រៀន*** ។

តបតាមកម្មវត្ថុ និង យោងខាងលើ សូមជំរាបលោកប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី ***អង្គការស្នាក់នៅស្ម័គ្រចិត្តជួយបង្រៀន*** ដែលមានអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលនៅផ្ទះលេខ***១៣២*** ក្រុមទី***១៤*** ភូមិ***ស្វាយ*** ឃុំ***កន្ទ្រាំង*** ស្រុក***ប្រាសាទបាគង*** ខេត្ត***សៀមរាប*** នោះហើយ។ ***អង្គការស្នាក់នៅស្ម័គ្រចិត្តជួយបង្រៀន*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាអង្គការអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបំរើអោយគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន អង្គការស្នាក់នៅស្ម័គ្រចិត្តជួយបង្រៀន ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមលោកប្រធានជ្រាបជាព័ត៌មាន ។
សូមលោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាលាខេត្តសៀមរាប
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ